# គុណបងយើង

## Brother's Gratitude

By Venerable Ponn Sovanna

កាលប្អូននៅពីក្មេង	បងនាំលេងមិនឲ្យព្រួយ
ខុសត្រូវបងអ្នកជួយ	ប្អូនរំអួយពួយតែយំ។
បើម៉ែឲ្យមួយរៀល	ប្អូនចំទាលទារទិញនំ
ទិញបានផ្អើលចាស់ទុំ	ប្អូនស្រែកយំទារច្រើនជាង។
ម៉ែថានំចំណី	កូនត្រូវលៃទុករវាង
បងប្អូន ត្រូវជៀសវាង	ការមិនទៀងក្រែងវង្វេង។
បងពប្អូនត្រាក់ៗ	ផ្ទៃពោះបាក់រលីងធេង
ប្អូនយំឃ្វានចង់គេង	មិនព្រមលេងស្រែកឡូឡា។
ម៉ែព្នអាតូចយំ	ជេរអាធំវ៉ៃឆ្ងេឆ្ងា
ថាឯងលេងឯណា	មិនស្រវាឆាប់លើកវា។
បងខំលួងស្ទើរស្លាប់	ប្អូនមិនស្តាប់ប្រឹងយំទារ
គ្រប់ពេលរាល់វេលា	ស្រែកបញ្ជាតាមចំណង់។
បងពផ្ទៃចង្កេះ	ជូនធ្វើសេះព្រោះប្អូនចង់
ហេវហត់ពេលថ្ងៃត្រង់	អ្វីប្អូនចង់មិនប្រឆាំង។
កិកកុកអុកឡុកបង	យំជេរផងស្រែកខ្លាំងៗ
ខ្មោះខ្នរជួបចិត្តខ្លាំង	អួតតតាំងតបបងវិញ។
រំអុកយំរំអួយ	ខ្ទៃតដូចខ្ជួយកន្ទុយស្មេញ
ព្រោះពោះមិនទាន់ពេញ	នៅកន្ទេញកន្ទក់ចិត្ត។
បងខំលោមអង្វរ	មិនតបតដោយអាណិត
ស្រឡាញ់ថ្នមផ្តេកផ្តិត	បងសុខចិត្តអត់មាត់ឯង។
លើកប្អូនបញ្ជិះក	ឱបបីទ្រពបន្ទែង
ទំលើធ្វើជាល្បែង	នាំប្រលែងលេងលំហែរ។
ស្រមោចខាំប្អូនផង	ថាអាបងមិនចេះថែ

ឯងបងតំណាងម៉ែ បងត្រូវតែមើលខុសត្រូវ។
ជាក្មេកជាច្រមុះ ការត្រូវខុសគិតម៉ែឪ
គាត់នៅឬមិននៅ គឺឯងត្រូវជួយគ្រងស្នួន។
ម៉ែឪគាត់ខំរក មិនបានមកថ្នមថៃថ្នូន
ហត់នឿយមិនគិតខ្លួន កូនបីបួនយំចាំស៊ី។
កូនបងជួយម៉ែឪ មើលខុសត្រូវកូនមួយពីរ
នៅចាំយំហ៊ុៗ ទារតែស៊ីតាមចិត្តឃ្លាន។
មុខរីងខឹងឡូឡា ស្រែកឡាំប៉ាទារបំពាន
បងលោមថាមិនមាន រឹតតែឃ្លានស្រែកឮខ្លាំង។
ខ្វះហ៊ានវ៉ៃបងវិញ ដល់ធំពេញមានកម្លាំង
ដៀលត្មិះឈ្លោះប្រឆាំង តបតតាំងអាងសាច់ដុំ។
ភ្លេចអស់កាលនៅក្មេង បងនាំលេងបញ្ចុកនំ
បងសុំមួយកូនដុំ ឯងស្រែកយំពុំព្រមឲ្យ។
បងព្វួយចង្កេះ លើកបញ្ជិះអៀវពីក្រោយ
នៅយំស្រែកដង្ហោយ ឲ្យបងរត់បោលធ្វើសេះ។
បងចុកសព្វសរសៃ ព្វួយដៃស្ទើររលេះ
ប្អូនជាប់នឹងចង្កេះ ធ្វើមាត់ស្ពេះយំហ៊ីៗ។
ទារបាយចំណីនំ ចេះតែយំឃ្លានតែស៊ី
ពង្វក់បងវក់វី ពេលបានស៊ីទើបបាត់មាត់។
បានស៊ីប្រឹងដំទែង លេបតែឯងឲ្យបងអត់
បងពដើរនឿយហត់ ត្រូវតែមាត់ម៉ែឪជេរ។
បងខំពុំដាក់ដៃ រាល់តែថ្ងៃមិនទំនេរ
ព្រឹកឡើងពោះទទេ ម៉ែស្រែកជេរគេចអត់បាយ។
គុណបងច្រើនគេភ្លេច គេរំលេចឪពុកម្ដាយ
ខ្ញុំ បងធ្មៀតបកស្រាយ ក្រោមគុណម្ដាយគុណឪពុក។
ក្រែងប្អូនៗគេគិត គេអាណិតកំណត់ទុក
ក្រៅពីគុណម៉ែពុក កត់ត្រាទុកគុណបងផង៕